ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិដឹកនាំការងារ
កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ

លេខ ០៣៧ គសក /គ.ជ.ដ.ប

រាជធានីភ្នំពេញ ថ្ងៃទី១៤ ខែមេសា ឆ្នាំ២០០៨

# សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតក្រុមពិគ្រោះយោបល់បច្ចេកទេសអន្តរក្រសួង សំរាប់ជួយគាំទ្រ ដល់ការអនុវត្តគម្រោងសាកល្បងការិយាល័យច្រកចេញចូលតែមួយ និងការិយាល័យប្រជាពលរដ្ឋនៅថ្នាក់ស្រុក ខណ្ឌ

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
## ប្រធានគណៈកម្មាធិការជាតិដឹកនាំការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ នស/រកត/០៣០៦/១២២ ចុះថ្ងៃទី ២២ ខែ មីនា ឆ្នាំ ២០០៦ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/ ០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យ នស/រកត/០៨០៦/៣៩៥ ចុះថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០០៦ ស្តីពីការបង្កើតគណៈកម្មាធិការជាតិដឹកនាំការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ។
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ

## សម្រេច

**ប្រការ១ :** ត្រូវបានបង្កើត "**ក្រុមពិគ្រោះយោបល់បច្ចេកទេសអន្តរក្រសួង**" សំរាប់ជួយគាំទ្រដល់ការអនុវត្តគម្រោងសាកល្បងការិយាល័យច្រកចេញចូលតែមួយ និងការិយាល័យប្រជាពលរដ្ឋនៅថ្នាក់ស្រុក ខណ្ឌ ដែលមានសមាសភាពដូចខាងក្រោម ៖

| | | | |
|---|---|---|---|
| ១- | ឯកឧត្តម **សក់ សេដ្ឋា** | អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន ក្រសួងមហាផ្ទៃ | ជាប្រធាន |
| ២- | ឯកឧត្តម **រ័ត្ន សារិន** | អនុរដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | ជាសមាជិក |
| ៣- | ឯកឧត្តម **លេង វី** | អគ្គនាយករងរដ្ឋបាលមូលដ្ឋាន ក្រសួងមហាផ្ទៃ | ជាសមាជិក |
| ៤- | ឯកឧត្តម **ម៉ាន់ ចំរើន** | អគ្គនាយករងរដ្ឋបាលមូលដ្ឋាន ក្រសួងមហាផ្ទៃ | ជាសមាជិកអចិន្ត្រៃយ៍ |

៥- ឯកឧត្តម **ប៉ូល ពីខូ** អគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល ជាសមាជិក

៦- លោក **សួង សារុណា** អគ្គនាយករងរដ្ឋបាលនិងហិរញ្ញវត្ថុ ក្រសួងអប់រំ យុវជន និងកីឡា ជាសមាជិក

៧- លោក **សោម សារ៉ែន** អគ្គនាយករងរដ្ឋបាលនិងហិរញ្ញវត្ថុ ក្រសួងសុខាភិបាល ជាសមាជិក

៨- លោក **លីវ ប៊ុនហៃ** ប្រធាននាយកដ្ឋានថវិកាមូលដ្ឋាន ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាសមាជិក

៩- លោក **ខួង វីរៈ** ប្រធាននាយកដ្ឋានបុគ្គលិក និងអភិវឌ្ឍធនធានមនុស្ស ក្រសួងទេសចរណ៍ ជាសមាជិក

១០- លោក **ឃឹម សិរីវឌ្ឍ** ប្រធាននាយកដ្ឋានបុគ្គលិក ក្រសួងពាណិជ្ជកម្ម ជាសមាជិក

១១- លោក **ខឹម ចិន្តា** ប្រធាននាយកដ្ឋានកិច្ចការរដ្ឋបាល ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជាសមាជិក

១២- លោក **កែវ សុវត្ថិ** ប្រធាននាយកដ្ឋានកិច្ចការឧស្សាហកម្ម ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ជាសមាជិក

១៣- លោក **ម៉ុក គុណវឌ្ឍ** ប្រធាននាយកដ្ឋាននីតិកម្ម ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ជាសមាជិក

១៤- លោក **មាស ម៉ូនីកា** ប្រធាននាយកដ្ឋានបុគ្គលិក ក្រសួងសាធារណការ និងដឹកជញ្ជូន ជាសមាជិក

**ប្រការ២ :** លេខាធិការដ្ឋាន គ.ជ.វ.វ អាចស្នើសុំតែងតាំងសមាជិកបន្ថែមទៀតតាមការចាំបាច់ ។

**ប្រការ៣ :** ក្រុមពិគ្រោះយោបល់បច្ចេកទេសអន្តរក្រសួង មានតួនាទី និងភារកិច្ចដូចខាងក្រោម :

- ទទួលខុសត្រូវក្នុងការពិនិត្យ និងពិភាក្សាលើសេចក្ដីព្រាងគោលនយោបាយ និងលិខិតបទដ្ឋាននានា ពាក់ព័ន្ធនឹងការពង្រឹង និងការពង្រីកបន្ថែមការិយាល័យច្រកចេញចូលតែមួយ និងការិយាល័យប្រជាពលរដ្ឋ ដែល រៀបចំឡើងដោយក្រុមគាំទ្រថ្នាក់ស្រុក ខណ្ឌ និងផ្ដល់អនុសាសន៍ជូន គ.ជ.វ.វ ដើម្បីពិនិត្យ និងអនុម័ត ។
- សហប្រតិបត្តិការ និងទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយនឹងលេខាធិការដ្ឋាន គ.ជ.វ.វ ដែលទទួលខុសត្រូវក្នុងការប្រតិបត្តិនៃគម្រោង "ការិយាល័យច្រកចេញចូលតែមួយ និងការិយាល័យប្រជាពលរដ្ឋ" ។
- ពិភាក្សា និងលើកយោបល់ជូនក្រសួង ស្ថាប័នពាក់ព័ន្ធ និង គ.ជ.វ.វ អំពីការធ្វើប្រតិភូកម្មមុខងារ និងសិទ្ធិអំណាចដល់រដ្ឋបាលស្រុក ខណ្ឌគោលដៅ ។
- សិក្សាស្រាវជ្រាវ និងលើកយោបល់ជូនក្រសួង ស្ថាប័នពាក់ព័ន្ធ និង គ.ជ.វ.វ អំពីការធ្វើបច្ចុប្បន្នភាពនៃការធ្វើប្រតិភូកម្ម និងការកំណត់កំរៃសេវាដែលប្រមូលដោយរដ្ឋបាលស្រុក ខណ្ឌគោលដៅ អោយស្របទៅតាមការវិវត្តនៃសេដ្ឋកិច្ច និងសេចក្ដីត្រូវការរបស់ប្រជាពលរដ្ឋ ។
- សម្របសម្រួលជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ខេត្ត ក្រុងគោលដៅ និងមន្ទីរ អង្គភាពជំនាញនានា នូវរាល់បញ្ហាដែលពាក់ព័ន្ធនឹងការអនុវត្តគម្រោងនេះ ។
- តាមដាន និងត្រួតពិនិត្យជាប្រចាំនូវការអនុវត្តរាល់សកម្មភាព និងការរីកចំរើននៃគម្រោង ។
- រៀបចំរបៀបរបបធ្វើការងារ និងកិច្ចប្រជុំរបស់ខ្លួន ។
- រៀបចំ និងចូលរួមសិក្ខាសាលាថ្នាក់ជាតិ និងកិច្ចប្រជុំនានា ដែលពាក់ព័ន្ធនឹងការរៀបចំថ្នាក់ស្រុក ខណ្ឌ ។
- ណែនាំ និងផ្ដល់យោបល់ដល់ក្រុមគាំទ្រថ្នាក់ស្រុក ខណ្ឌអំពីការអនុវត្តគម្រោងនេះសំដៅធ្វើយ៉ាងណាអោយការអនុវត្តគម្រោងប្រកបដោយជោគជ័យ ស្របតាមលិខិតបទដ្ឋានដែលមាន ។

**ប្រការ៤ :** រដ្ឋមន្ត្រី រដ្ឋលេខាធិការ នៃក្រសួង ស្ថាប័នពាក់ព័ន្ធ ក្រុមការងារ គ.ជ.វ.វ លេខាធិការដ្ឋាន គ.ជ.វ.វ និងសាមីខ្លួនដូចមានចែងក្នុងប្រការ១ខាងលើ ត្រូវអនុវត្តសេចក្ដីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគ.ជ.វ.វ**

**ស ខេង**

**កន្លែងទទួល :**

- ទីស្ដីការគណៈរដ្ឋមន្ត្រី (ដើម្បីជូនជ្រាប)
- ដូចប្រការ ៤ (ដើម្បីអនុវត្ត)
- ឯកសារ - កាលប្បវត្តិ